

កុមារីគង្គាមានអាយុ១២ឆ្នាំ។ នាងកំព្រាម្តាយ។ នាងរស់នៅជាមួយឪពុក និងបងប្រុស លើបឹងទន្លេសាប។

អ្វីៗនៅទីនោះសុទ្ធតែអណ្តែតលើទឹក។ សាលារៀន មណ្ឌលសុខភាព វត្ត និងសួនដំណាំ...ជាដើម។



ឪពុកគង្គាជាអ្នកដែលពូកែចាប់ត្រី។
បងប្រុសរបស់នាងជាអ្នកដែលពូកែអុំទូក។ រៀងរាល់ព្រឹក ឪពុក
និងបងប្រុសតែងចេញពីផ្ទះទៅរកត្រី។ ចំណែកឯគង្គានៅចាំផ្ទះ
និងថែរក្សាសួនដំណាំ។



ជារឿយៗ គង្គាតែងនិយាយសុំឪពុក និងបងប្រុសទៅជាមួយ។

«ខ្ញុំចង់ទៅរកត្រីដែរ។» «ទេ! ទៅរកត្រីជាការងារពិបាកណាស់។

កូនឯងនៅផ្ទះស្រោចដំណាំល្អជាង។ ពុកចង់ញ៉ាំផ្លែល្ហុងដែលកូនដាំ។»

«អូនឯងត្រូវនៅមើលថែប៉េងប៉ោះសម្រាប់បង។ »



រដូវវស្សាចូលមកដល់។ ភ្លៀងធ្លាក់ស្ទើររាល់ថ្ងៃ។
ទឹកបឹងឡើងលិចគ្រប់ទីកន្លែង។



ថ្ងៃមួយ ឪពុក និងបងប្រុសបានចេញទៅរកត្រី។ ស្រាប់តែ
គង្គាស្រែកខ្លាំងៗ។ «តើសួនដំណាំខ្ញុំហាត់ទៅណាហើយ?»
នាងរត់ទៅមើលជុំវិញផ្ទះ ប៉ុន្តែមិនឃើញសួនដំណាំទេ។
នាងក្រឡេកទៅឆ្ងាយឃើញសួនដំណាំស្លុងៗ។



គង្គាក៏សម្រេចចិត្តយកទូកចែវតាមរកសួនដំណាំ។
នាងខំចែវតាមពីក្រោយសួនដំណាំ។ ប៉ុន្តែសួន
ដំណាំចេះតែអណ្តែតទៅមុខយ៉ាងលឿន។ «សួនអើយសួន! ចាំខ្ញុំផង។»
នាងខំចែវកាន់តែញាប់ជាងមុន។



នៅកណ្តាលផ្ទៃបឹង រលកបោកខ្លាំងៗ។ ទូកនាងម្តងវ្រេទៅឆ្វេង
ម្តងវ្រេទៅស្តាំ។ ទឹកចូលពេញក្នុងទូករបស់គង្គា។
នាងខំប្រឹងហាចទឹកចេញយ៉ាងរហ័ស ហើយចែវបន្តទៀត។ថ្ងៃកាន់តែក្តៅ
គង្គាហេវហត់ខ្លាំងណាស់។ សួនដំណាំមិនព្រមឈប់សោះ
វារសាត់លឿនទៅៗ។



មួយសន្ទុះក្រោយមក សួនដំណាំក៏ឈប់នៅមួយកន្លែង។
គង្គាសប្បាយចិត្តណាស់ ក៏អុំទូក សំដៅវាយ៉ាងលឿន។
ពេលទៅដល់ក្បែរវា នាងបោះខ្សែចងទូកជាប់បំពង់ឫស្សី។ បន្ទាប់មក
គង្គាហក់ចូលទៅក្នុងសួន។
ស្រាប់តែសួនដំណាំរសាត់ទៅមុខបន្តទៀតយ៉ាងលឿន។



គង្គាឆ្ងល់ ៖ «តើមានរឿងអីកើតឡើង? នាងដកដង្ហើមវែងៗ ហើយលោតចូលក្នុងទឹកប្ូរង។ នាងសម្លឹងមើលឆ្វេងស្តាំ ស្រាប់តែឃើញត្រីគល់រាំងធំមួយ។



វាកំពុងអូសសួនដំណាំរបស់នាង។ «គឺត្រីនេះទេតើ
ដែលលួចសួនដំណាំរបស់ខ្ញុំ!» គង្គាគិតក្នុងចិត្ត។
គង្គាខំហែលតាមពីក្រោយ ប៉ុន្តែត្រីហែលទៅមុខយ៉ាងលឿន។ មួយសន្ទុះ
ស្រាប់តែវាឈប់ហែល ហើយនៅស្ងៀមមួយកន្លែង។



នាងភ្ញាក់ព្រឺត ព្រោះឮសំឡេងចេចាចនៅពីលើ។ នាងងើយមុខឡើង

ក៏ឃើញហ្វូងស្វា ជាច្រើន។ «អូ! ខ្ញុំយល់ហើយ។

ត្រីយក្សយកសួនដំណាំខ្ញុំ ដើម្បីជួយហ្វូងស្វា។»

ត្រីគល់រាំងព្រួសទឹកទៅលើ ជាសញ្ញាយល់ព្រម។



គង្គាប្រញាប់សួរបន្ត ៖ «ឯងចង់នាំពួកគេទៅព្រៃធំ តើមែនទេ?»

ត្រីគល់រាំងព្រួសទឹកទៅលើ យ៉ាងខ្លាំង។

ហ្វូងស្វានាំគ្នារត់ឡើងមកលើសួនដំណាំ។ គង្គាស្រែក

«កុំសីផ្លែល្ហុងនិងប៉េងប៉ោះរបស់ខ្ញុំ!» តែពួកស្វាមិនស្តាប់នាងទេ។

ពួកវាឃ្លានយ៉ាងខ្លាំង ហើយសីដំណាំរបស់នាងអស់។



មកដល់ច្រាំងព្រៃធំ ពួកស្វាប្រញាប់រត់ឡើងលើមែកឈើ។

ពួកវានាំគ្នាបេះផ្លែឈើល្អៗ មកដាក់ពេញសួនច្បារ។

គង្គាសប្បាយចិត្តយ៉ាងខ្លាំង។



នាងក៏ចែវទូកត្រលប់ទៅផ្ទះវិញ។ ឪពុក និងបងប្រុសរីករាយ
ពេលឃើញគង្គាមកផ្ទះវិញ។



គង្គាសួរឪពុកនិងបងប្រុសនាងសារជាថ្មី ៖ «ពុក បងប្រុស! តើខ្ញុំអាចទៅនេសាទដែរបានទេ?» បងប្រុសនាងញញឹម ហើយនិយាយទៅកាន់ឪពុកនាង ៖ «ពុក! គង្គាអាចអុំទូកកាត់បឹងបាន។ ដូច្នេះ នាងប្រាកដជាអ្នកអុំទូកដ៏ពូកែម្នាក់!» «កូនស្រីពុកក្លាហានណាស់ អាចធ្វើអ្វីៗបានទាំងអស់!»

រឿង សួនបណ្តែតទឹក សមាជិកក្រុមហាក់កាសន៖ អៀម ទិត្យសីហា (អ្នកនិពន្ធ) ណាន សាង (វិចិត្រករ) អ៊ុន ដាលី (អ្នករចនា)

រចនាប្លង់ចុងក្រោយដោយ៖ អ៊ុង គាមសោ

សូមថ្លែងអំណរគុណជាពិសេសដល់ហ៊ុយ រតនា សឿមកក្កដា ជូ ជីនិត និងក្រុមការងារ CamAnt Technology ចំពោះការជួយគាំទ្រដល់កម្មវិធីហាក់កាសនសៀវភៅអេឡិចត្រូនិច តោះអាន! ដែលបានធ្វើឡើងក្នុងទីក្រុងភ្នំពេញ កាលពីថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០១៧។

© មូលនិធិអាស៊ីឆ្នាំ២០១៧។រក្សាសិទ្ធិមួយចំនួន។

ស្នាដៃនេះត្រូវបានការពារក្រោមអាជ្ញាប័ណ្ណប្រភេទ Creative Commons Attribution-NonCommercial 4.0 (http://creativecommons.org/licenses/by-nc/4.0/) ។ អ្នកអាចចម្លង (ថតចម្លង និងចែកចាយបន្តឯកសារនេះ ដោយមធ្យោបាយ ឬក្នុងទម្រង់អ្វីក៏បាន)ដោយសេរី និងធ្វើការកែសម្រួល (លាយបញ្ចូលជាមួយខ្លឹមសារផ្សេងទៀត បម្លែង និងបង្កើតជាឯកសារផ្សេងៗទៀត) លបំណងមិនមែនពាណិជ្ជកម្ម។អ្នកចេញអាជ្ញាប័ណ្ណមិនអាចដកហូតសេរី ដរាបណាអ្នកគោរពទៅតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណដូចខាងក្រោម៖ សេចក្តីថ្លែងអំណរគុណ-អ្នកត្រូវសរសេរពីប្រភពឯកសារឲ្យបានសមស្រប បង្ហាញពីតំណភ្ជាប់ទៅកាន់អាជ្ញាប័ណ្ណ និងបញ្ជាក់ពីការផ្លាស់ប្តូរខ្លឹមសារ ប្រសិនបើមាន។

អ្នកអាចធ្វើបែបនេះ តាមវិធីណាក៏បានដែរសមស្រប ប៉ុន្តែពុំមានន័យថា អ្នកផ្តល់អាជ្ញាប័ណ្ណគាំទ្រដល់អ្នក ឬដល់ការប្រើប្រាស់របស់អ្នកនោះទេ។
មិនមែនលក្ខណៈពាណិជ្ជកម្ម-អ្នកមិនអាចប្រើប្រាស់ឯកសារនេះ សម្រាប់គោលបំណងពាណិជ្ជកម្មឡើយ។

Floating Garden Hackathon team: Iem Tithseiha (Writer), Nan Sang (Illustrator), Un Daly (Graphic Designer) Final layout by: Ong Keamesa

Special thanks to Huy Rattana, Soeurm Kakada, Chou Chinith, and the CamAnt Technology team for their help with the Let’s Read! E-book Hackathon, which took place in Phnom Penh on 19 March 2017.

© The Asia Foundation, 2017. Some rights reserved. This work is licensed under a Creative Commons Attribution-NonCommercial 4.0 Licence (http://creativecommons.org/licenses/by-nc/4.0/). You are free to share (copy and redistribute the material in any medium or format) and adapt (remix, transform, and build upon the material) this work for any non-commerical purpose. The licensor cannot revoke these freedoms as long as you follow the following license terms:

Attribution — You must give appropriate credit, provide a link to the license, and indicate if changes were made. You

may do so in any reasonable manner, but not in any way that suggests the licensor endorses you or your use.
NonCommercial — You may not use the material for commercial purposes.

តោះអាន!

The Asia Foundation

Generously Supported By

Smart